00356981

ឯកសារៈ D 97/3/4

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de réception): 30 / 07 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA...

**ពត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៩

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 31 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់ អៀង សារី ស្នើសុំដាក់ទណ្ឌកម្មទៅលើសហព្រះរាជអាជ្ញា ដែលបាននាំឲ្យតុលាការវង្វេងវង្វាន់ នៅក្នុងសេចក្តីសង្ខេបបន្ថែមរបស់ខ្លួនស្តីពីសហឧក្រិដ្ឋកម្មរួម**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

លោក **អៀង សារី** តាមរយៈមេធាវីការពារក្តីរបស់ខ្លួន ("មេធាវីការពារក្តី") អនុលោមទៅតាមវិធាន ៣៥(១) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") តទៅនេះ សូមដាក់ចម្លើយតបនេះចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ អៀង សារី ស្នើសុំដាក់ទណ្ឌកម្មទៅលើសហព្រះរាជអាជ្ញា ដោយចោទប្រកាន់ថាបានបំភាន់តុលាការ ទាក់ទងនឹងទ្រឹស្តីសហកម្មឧក្រិដ្ឋរួម ("ចម្លើយតបរបស់ កសព") ដែលដាក់នៅថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៩។ នៅក្នុងចម្លើយរបស់ខ្លួន កសព គេចវេសដោយចេតនាពីការឆ្លើយតបទៅនឹងការចោទប្រកាន់ដោយផ្ទាល់ ដែលស្នើឡើងដោយសំណើរបស់មេធាវីការពារក្តីដែលលើកឡើងថា លោកសាស្ត្រាចារ្យ Scharf និង សមាជិកនានារបស់ កសព បានបំភាន់ កសចស ឱ្យយល់ខុស ដោយដឹងជាមុន និង ដោយមានចេតនា[1]។ កសព ស្វែងរកការបង្វែរអារម្មណ៍របស់ កសចស ពីការចោទប្រកាន់ដ៏ធ្ងន់ធ្ងរនេះ តាមរយៈ ការចោទសួរពីប្រភពព័ត៌មានដែលបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់។ គ្មានការអះអាងដែលមិនច្បាស់លាស់ទាក់ទងនឹង "ការយល់ដឹងពីទ្រឹស្តីសហកម្មឧក្រិដ្ឋរួម ("JCE")" របស់ កសព[2] អាចច្រានចោល កសចស មិនឱ្យបំពេញករណីកិច្ចដ៏មានសារៈសំខាន់របស់ខ្លួន ក្នុងការធានាថា ដំណើរការរឿងក្តីត្រូវតែមាន "យុត្តិធម៌ និង គោរពគោលការណ៍នៅចំពោះមុខ"[3] និង ដាក់ទណ្ឌកម្មទៅលើភាគីណាម្នាក់ដែលចូលជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាលតុលាការដោយចេតនា[4]។

## I. ឧទ្ទីករណ៍

1. ចំនុចស្នូលនៃការចោទប្រកាន់នៅក្នុងសំណើ គឺថាលោកសាស្ត្រាចារ្យ Scharf បានសារភាពជាសាធារណៈថា កសព មានចេតនាលាក់ទុកនូវមូលដ្ឋានសំអាងច្បាប់ពាក់ព័ន្ធ ទាក់ទងនឹងការទទួលយក និង វិសាលភាពនៃគោលការណ៍នានាមកពីធម្មនុញ្ញ និង សាលក្រមនានារបស់តុលាការនូរ៉ឹមប៊ែក ("គោលការណ៍នូរ៉ឹមប៊ែក")។ ដូចដែលលោកសាស្ត្រាចារ្យ Scharf បានសារភាពក្នុងអំឡុងពេលលោកធ្វើបាឋកថាមួយ មូលដ្ឋានសំអាងច្បាប់ត្រូវបានលាក់ទុកដោយសារតែវាធ្វើឱ្យខូច

---

[1] ករណីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើរបស់ អៀង សារី ស្នើសុំដាក់ទណ្ឌកម្មក្រោមវិធាន ៣៥ ទៅលើសហព្រះរាជអាជ្ញាចំពោះការនាំឱ្យតុលាការយល់ខុស នៅក្នុងសេចក្តីសង្ខេបបន្ថែមរបស់ពួកគេចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ និង ថ្ងៃទី ២៩ ខែ មិថុនា ២០០៩ ទាក់ទងនឹងច្បាប់ស្តីពីសហកម្មឧក្រិដ្ឋកម្មរួម ("សំណើ")។

[2] កថាខណ្ឌទី ៣ ចម្លើយតបរបស់ កសព ។

[3] វិធាន ២១(១)(ក)។

[4] វិធាន ៣៥(១)។

ខាតដល់ឋានៈរបស់ JCE នៅក្នុងទម្លាប់ច្បាប់អន្តរជាតិ ដែលមានចែងនៅក្នុងសេចក្តីសង្កេតបន្ថែមរបស់ខ្លួនទាក់ទងនឹង JCE[5]។ មិនអាចបដិសេធបាន នេះគឺជាចំណុចស្នូលនៃភាពចម្រូងចម្រាស់ទាក់ទងនឹងថា តើ JCE អាចអនុវត្តបាននៅ អវតក ដែរឬទេ ៖ "បញ្ហាជាសារវន្តនៅក្នុងវិវាទនេះ គឺថាតើ JCE ជាផ្នែកមួយនៃទម្លាប់ច្បាប់អន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬទេ [...] លើកលែងតែចំណោទនេះត្រូវបានគេបកស្រាយនៅក្នុងន័យវិជ្ជមាន បើមិនអញ្ចឹងទេទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌនេះ ពិតជាមិនអាចត្រូវបានគេប្រើប្រាស់ប្រឆាំងនឹងបុគ្គលទាំងឡាយនោះដែលត្រូវបានគេចោទប្រកាន់នៅចំពោះមុខ អ.វ.ត.ក ឡើយ។[6]។

2. ជំនួសឱ្យការថ្លែងប្រាស្រ័យដោយផ្ទាល់ទៅនឹងការចោទប្រកាន់ដែលថា កសព បានពិភាក្សា ហើយក្រោយមកបានសម្រេចចិត្តលាក់បាំងពី កសចស នូវអត្ថិភាពនៃសេចក្តីសម្រេចមួយរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ 488(V) ("សេចក្តីសម្រេចក្រោយមករបស់ UNGA")[7] ដែលបានធ្វើខូចខាតដល់ឋានៈរបស់ JCE នៅក្នុងទម្លាប់ច្បាប់អន្តរជាតិ ចម្លើយតបរបស់ កសព ធ្វើនូវសេចក្តីថ្លែងការណ៍ដែលសុទ្ធតែគ្មានខ្លឹមសារ មិនគ្រប់លក្ខណៈ ឬ មិនច្បាស់លាស់ ដែលទាំងអស់នេះតម្រូវឱ្យមានការបំភ្លឺ។

**ក. ការអះអាងរបស់ កសព ដែលថាសេចក្តីសង្កេតបន្ថែមឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវពីការយល់ដឹងរបស់ពួកគេទៅលើច្បាប់ស្តីពីសហកម្មឧក្រិដ្ឋរួម នៅថ្ងៃដាក់ការសង្កេតនោះ[8]**

3. កសព អះអាងថា "ខណៈដែលគ្មានសេចក្តីថ្លែងសំអាងខាងផ្លូវច្បាប់ណាមួយ ដែលទាមទារថាត្រូវយោងទៅលើមូលដ្ឋានសំអាងច្បាប់ទាំងអស់ដែលអាចរកបានស្តីពីបញ្ហានេះ [...] សេចក្តីសន្និដ្ឋានបន្ថែមមានដាក់បញ្ចូលនូវការត្រួតពិនិត្យយ៉ាងទូលំទូលាយអំពីមូលដ្ឋានសំអាងផ្លូវច្បាប់នានា ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា JCE គឺជាផ្នែកមួយនៃទំនៀមទម្លាប់ច្បាប់

---

[5] ករណីរបស់ អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស ការសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសហកម្មឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ("ការអង្កេតបន្ថែមរបស់កសព") ដូចដែលបានសំអាងនៅក្នុងកថាខណ្ឌទី ១ នៃសំណើ។

[6] កថាខណ្ឌទី ២ នៃសំណើ ។

[7] សេចក្តីសម្រេចលេខ 488(V) របស់មហាសន្និបាតរបស់អង្គសហប្រជាជាតិលើកទី ៣២០ អនុម័តថ្ងៃទី ១២ ខែ ធ្នូ ១៩៥០។

[8] កថាខណ្ឌទី ៣ នៃចម្លើយតបរបស់ កសព ។

00356984



អន្តរជាតិក្នុងអឡុងឆ្នាំ១៩៧៥-១៩៧៩"[9]។ ការអះអាងបែបនេះគឺពិតជាខុសយ៉ាងច្បាស់។ ការចោទប្រកាន់ដែលធ្វើឡើងនៅក្នុងសំណើ គឺមិនសំដៅថា កសព ខកខានមិនបានយោងទៅលើមូលដ្ឋានច្បាប់ទាំងអស់ដែលអាចរកបាន ទាក់ទងនឹងរាល់ទិដ្ឋភាពរបស់ JCE នោះទេ។ ផ្ទុយទៅវិញ ការចោទប្រកាន់ពិតប្រាកដគឺថា កសព បានអះអាងថាសេចក្ដីសម្រេចរបស់ UNGA 95(I) "បានគាំទ្រជាឯកច្ឆ័នដល់គោលការណ៍មកពីធម្មនុញ្ញ និង សាលក្រមនានារបស់តុលាការនូរឹមប៊ែក"[10] ខណៈដែលខកខានដោយចេតនាមិនបញ្ចូលនៅក្នុងសេចក្ដីសង្កេតបន្ថែមរបស់ខ្លួន នូវអត្ថិភាពដែលគេបានដឹងអំពី សេចក្ដីសម្រេចក្រោយមករបស់ UNGA ដែល"ជាក់ស្ដែងពិតជាផ្ទុយនឹងគោលជំហររបស់ កសព ទាក់ទងនឹងភាពអាចអនុវត្តបាននៃសហកម្មឧក្រិដ្ឋរួម"[11]។ ដោយពឹងផ្អែកទាំងស្រុងទៅលើសេចក្ដីសម្រេចរបស់ UNGA 95(I) ដែលជាសេចក្ដីសម្រេចសម្រាប់អនុវត្ត/គ្រប់គ្រង នោះ កសព បានបង្កើតករណីយកិច្ចមកលើខ្លួនឯងក្នុងការពញ្ញាក់ដល់ស្មារតី កសចស ទៅលើសេចក្ដីសម្រេចក្រោយមកទៀតរបស់ UNGA ដែលធ្វើឲ្យខូចខាតដល់ កសព ខ្លួនឯង។ តែចំណុចនេះគេមិនបានធ្វើទេ ព្រោះគេមានចេតនាធ្វើដូច្នោះ។

4. កសព បានបង្ហាញឲ្យដឹងដោយប្រយោលថា ពីហេតុដែលខ្លួនមិនពញ្ញាក់ដល់ស្មារតី កសចស អំពីអត្ថិភាពនៃសេចក្ដីសម្រេចក្រោយមករបស់ UNGA ប៉ុន្តែ កសព ជ្រើសរើសយកការផ្ដល់ទៅឲ្យ កសចស តែមូលដ្ឋានសំអាងផ្លូវច្បាប់ "ដើម្បីជ្រោមជ្រែងដល់សេចក្ដីសន្និដ្ឋានរបស់ខ្លួនដែលថា សហកម្មឧក្រិដ្ឋរួមជាផ្នែកមួយនៃទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥-១៩៧៩"[12]។ សមាជិកនានារបស់ កសព និង សាស្ត្រាចារ្យ Scharf មានចេតនាមិនខ្វាយខ្វល់ចំពោះករណីកិច្ចជាវិជ្ជមានរបស់ពួកគេ ក្នុងការបង្ហាញដល់តុលាការនូវមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលមិនគាំទ្រដល់សេចក្ដីសន្និដ្ឋានស្នូលរបស់ កសព ដែលជាករណីកិច្ចមួយមានចែងនៅក្នុងក្រមសីលធម៌ផ្នែកវិជ្ជាជីវៈទាំងអស់ដែលចងភ្ជាប់កាតព្វកិច្ចលើសមាជិកទាំងអស់របស់ កសព[13]។ ការអនុវត្តផ្ទុយពីនេះបង្កើតបានជា

---

[9] កថាខណ្ឌទី ៣ នៃចម្លើយតបរបស់ កសព ។

[10] កថាខណ្ឌទី ១២ ការសង្កេតបន្ថែមរបស់ កសព ។

[11] កថាខណ្ឌទី ៥ សំណើ ។

[12] កថាខណ្ឌទី ៣ ចម្លើយតបរបស់ កសព ។ (បញ្ជាក់បន្ថែម)។

[13] កថាខណ្ឌទី ៣ ដល់ទី ៩ ផ្នែក II នៃសំណើ។ គួរឲ្យចាប់អារម្មណ៍ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ *ព្រឹត្តិប័ត្រ ឌី ខែមបូឌៀដេលី* សាស្ត្រាចារ្យ Scharf បានផ្ដល់ទឡ្ហីករណ៍ថា ប្រសិនបើយុត្តិសាស្ត្រជាក់លាក់ដែលផ្ទុយទៅនឹងជំហររបស់គេគ្រប់គ្នា ដែលត្រូវ

ការធ្វេសប្រហែសចំពោះករណីយកិច្ចរបស់ពួកគេមិនបំភាន់តុលាការ[14]។ ខណៈដែល កសព អាច យល់ឃើញថា សេចក្តីសម្រេចក្រោយមករបស់ UNGA រំខាននិងធ្វើឱ្យខ្វាយខ្វល់ ដោយសារតែ សេចក្តីសម្រេចនេះធ្វើឱ្យអំណះអំណាងរបស់ខ្លួនទាក់ទងនឹងសហកម្មឧក្រិដ្ឋរួម ចុះខ្សោយជា បណ្តើរៗនោះ កសព មានករណីយកិច្ចយ៉ាងច្បាស់លាស់ក្នុងការពាំនាំនូវបញ្ហានេះទៅ កសចស បានដឹង។ ការខកខានក្នុងការអនុវត្តនូវករណីយកិច្ចនេះដោយចេតនា និង ដោយដឹងជាមុន នោះ កសព ត្រូវរងការដាក់ទណ្ឌកម្ម ស្របតាមវិធាន ៣៥(១)។

## ខ. ការអះអាងរបស់ កសព ថា ទាំងសហព្រះរាជអាជ្ញាខ្លួនឯងផ្ទាល់ ទាំងបុគ្គលិករបស់ខ្លួន មិនបានលាក់ទុក ឬផ្តល់យោបល់ទៅជនណាម្នាក់ឱ្យលាក់បំបាំងពីតុលាការនូវមូលដ្ឋានសំអាងផ្នែកច្បាប់ពាក់ព័ន្ធឡើយ [15]

5. សាស្ត្រាចារ្យ Scharf បានប្រកាសនៅក្នុងពេលគាត់ធ្វើបាឋកថា "គាត់ត្រូវបាន កសព ជួលឱ្យ បំពេញមុខងារជាជំនួយការពិសេសរបស់សហព្រះរាជអាជ្ញាបរទេស លោក Robert Petit អស់ រយៈពេលប្រហែល ៥ ឬ ៦ សប្តាហ៍នៅក្នុងចុងឆ្នាំ ២០០៨[16]។ គាត់ហាក់ដូចជាឈប់បំពេញការ ងារឱ្យ កសព ទៀតហើយ។ តាមរយៈ កសព វាមិនច្បាស់លាស់នោះទេ ថាតើសាស្ត្រាចារ្យ Scharf ត្រូវបានគេរាប់បញ្ចូលនៅក្នុងក្រុម"បុគ្គលិក"របស់ កសព ដែលមិនបានដឹងទាល់តែសោះ ពីការលាក់បំបាំងព័ត៌មានពីតុលាការដែរឬយ៉ាងណា[17]។ ចំពោះការដែលថា សាស្ត្រាចារ្យ Scharf ត្រូវបានដកចេញពីក្រុមនេះ ដោយសារតែគាត់មិនត្រូវបាន កសព ជួលឱ្យបំពេញការងារតទៅ

---

បានគេដឹងឮគ្រប់ៗគ្នា នោះយុត្តិសាស្ត្រទាំងនេះមិនចាំបាច់លាតត្រដាងទៅតុលាការទេ។ ចំណោទមិនស្ថិតនៅត្រង់ថា តើ សេចក្តីសម្រេចរបស់ UNGA ដែលគេមិនបានដាក់បញ្ចូលទៅហើយ ស្ថិតនៅក្នុងភាពស្រពិចស្រពិល ឬ ជាក់ស្តែងដែរឬទេ ប៉ុន្តែ ថាតើ កសព កាតព្វកិច្ចតាមក្រមសីលធម៌ (ethical obligation) មួយដែរឬទេ ដើម្បីពញ្ញាក់ស្មារតីរបស់ កសចស នោះ។ វិធាននៃក្រមសីលធម៌វិជ្ជាជីវៈរបស់គណៈមេធាវីនៃតំបន់ District of Columbia (វិសោធនកម្មដែលចូលជាធរមានអនុវត្ត នៅថ្ងៃទី១ ខែកុម្ភៈ ២០០៧) បានកាតព្វកិច្ចយ៉ាងច្បាស់លាស់ទៅលើសាស្ត្រាចារ្យ Scharf ។

[14] អាស្រ័យហេតុនេះ វាជាការរឿងគួរឱ្យភ្ញាក់ផ្អើលដែលថា សាស្ត្រាចារ្យច្បាប់ដ៏ល្បីល្បាញបែបនេះបែរជាធ្វើមិនអើពើពីក្រម សីលធម៌ផ្នែកកាតព្វកិច្ចទាំងឯងដ៏តឹងងល់។ សូមមើល Douglas Gillison *ព្រឹត្តិប័ត្រ ខ្មែរបូឌៀ ដេលី* "មេធាវីការពារក្តី ជំទាស់ការជួយគាំទ្រដល់ការបំភាន់ អវតក ចុះផ្សាយថ្ងៃទី ១៩ ខែ កក្កដា ២០០៩ ។

[15] កថាខណ្ឌទី ៤ នៃចម្លើយតបរបស់ កសព ។

[16] កថាខណ្ឌទី ៤ នៃសំណើសុំ។

[17] កថាខណ្ឌទី ៤ នៃចម្លើយតបរបស់ កសព ។

ទៀត នោះការអះអាងនេះ គឺមិនស្មោះត្រង់ទាល់តែសោះ។

6. តាមពិតទៅ ចម្លើយតបរបស់ កសព មិនច្បាស់លាស់ទាល់តែសោះ ថាតើគេបានពិគ្រោះយោបល់ជាមួយសាស្ត្រាចារ្យ Scharf អំពីការចោទប្រកាន់របស់មេធាវីការពារដែរឬក៏ទេនោះ។ វាអាចជារឿងសាមញ្ញាបំផុតសម្រាប់ កសព ក្នុងការផ្តល់សេចក្តីបញ្ជាក់ការពិតមួយ (Affidavit) ពីសាស្ត្រាចារ្យ Scharf ដែលក្នុងនោះគាត់ត្រូវបដិសេធជាឱឡារិកនូវអំណះអំណាងដែលបានធ្វើឡើងនៅក្នុងសំណើសុំ។ កសព មិនថ្លែងប្រាស្រ័យ ថាតើសាស្ត្រាចារ្យ Scharf បានជាប់ពាក់ព័ន្ធនៅក្នុងការតាក់តែងសេចក្តីព្រាងសេចក្តីសង្កេតបន្ថែមដែរឬយ៉ាងណានោះទេ និង មិនផ្តល់យោបល់អ្វីទៅលើការបាឋកថារបស់សាស្ត្រាចារ្យ Scharf ដែលបានលើកឡើងខាងលើនោះទេ។ តាមពិតទៅ កសព បានគេចវេសមិនថ្លែងប្រាស្រ័យទាំងស្រុងថាតើការបកស្រាយព្រឹត្តិការណ៍របស់សាស្ត្រាចារ្យ Scharf នោះត្រឹមត្រូវដែរ ឬ យ៉ាងណា និង ថាតើ កសព ពិតជាបានពិភាក្សាពីសេចក្តីសម្រេចលេខ 95(I) របស់ UNGA និង សេចក្តីសម្រេចក្រោយមកទៀតរបស់ UNGA ដែលធ្វើឱ្យអន្តរាយដល់ដោយផ្ទាល់ដល់សេចក្តីសម្រេចមុនដែរឬយ៉ាងណានោះ។ វាមិនលំបាកពេកទេដែល កសព ទាក់ទងជាមួយសាស្ត្រាចារ្យ Scharf ដោយហេតុថា សារព័ត៌មានកម្ពុជាក្នុងស្រុងអាចទាក់ទងសាស្ត្រាចារ្យ Scharf ដើម្បីសុំយោបល់របស់គាត់បាន។ *សារព័ត៌មាន ខឹមែបូឌា ដេលី* បានចុះផ្សាយអត្ថបទមួយដែលក្នុងនោះ សាស្ត្រាចារ្យ Scharf ត្រូវបានដកស្រង់សម្តីដោយផ្ទាល់ ដោយបានបដិសេធថា គាត់បាននិយាយ ឬ បានពោលបញ្ឆិតបញ្ឆៀងថា “បុគ្គលិកទាំងអស់នៅក្នុង [ការិយាល័យសហព្រះរាជអាជ្ញា] បានបំភាន់ចៅក្រមឱ្យយល់ច្រឡំដោយចេតនា”[18]។ ដោយមិនអាចជៀសបាន ទោះបី កសព បានបំពេញសកម្មភាពជាមួយនឹងការយកចិត្តទុកដាក់តិចតួចក៏ដោយ ក៏ប្រតិកម្មរបស់សាស្ត្រាចារ្យ Scharf គួរត្រូវបានដាក់បញ្ចូលទៅក្នុងចម្លើយតបរបស់ខ្លួនដែរ។

## ខ. ការអះអាងរបស់ កសព ថា មូលដ្ឋានផ្នែកអង្គហេតុនៃសំណើសុំ គឺ មិនគ្រប់គ្រាន់សោះ ដើម្បីស្នើសុំឲ្យមានការដាក់ទណ្ឌកម្ម នៅក្រោមវិធាន ៣៥(១)[19]

---

[18] *Supra*, note 13.

[19] កថាខណ្ឌទី ៧ នៃចម្លើយតបរបស់ កសព ។

7. កសព រិះគន់សំណើសុំថា ជា "ការចោទប្រកាន់មួយដែលមិនមានទម្ងន់" នៃការប្រមូលចងក្រងរួមគ្នា" របស់ទីប្រឹក្សាច្បាប់សម្រាប់ក្រុមការពារក្តី និង ភាគីទីបី"[20]។ ចេតនាកាត់បន្ថយភស្តុតាងប្រឆាំងនឹងសាស្ត្រាចារ្យ Scharf គឺគ្មានមូលដ្ឋានសំអាងអ្វីទាំងអស់។ សាក្សីទាំងពីរនាក់នេះបានផ្តល់ភស្តុតាងដែលសាស្ត្រាចារ្យ Scharf ហៅថា ភស្តុតាងបឋម និង ភស្តុតាងដោយផ្ទាល់។ សំណើសុំមិនត្រូវបានសំអាងទៅលើពាក្យសម្តីឮតៗគ្នា ពាក្យចចាមអារ៉ាម ឬ ការស្មានៗនោះទេ តែសំអាងទៅលើពាក្យសម្តីរបស់សាស្ត្រាចារ្យ Scharf ខ្លួនឯង ដែលទីប្រឹក្សាច្បាប់របស់ក្រុមមេធាវីការពារក្តី និង បុគ្គលម្នាក់ ទៀតបានឃើញ និង បានឮ។

## II. សេចក្តីសន្និដ្ឋាន និង សំណូមពរ

8. ទឡ្ហីករណ៍របស់ កសព ដែលថា "ចរិតលក្ខណៈនៃដំណើការនីតិវិធីគោលការណ៍ចំពោះមុខ (adversarial)"[21] អាចធ្វើយុត្តិកម្មដល់ការខកខានរបស់ខ្លួនក្នុងការបង្ហាញដល់ កសចស នូវសេចក្តីសម្រេចបន្ទាប់ក្រោយមករបស់មហាសន្និបាត អ.ស.ប គឺមិនសមហេតុផលឡើយ។ កសព អះអាងថា ដោយសារតែមេធាវីការពារក្តី មានឱកាសគ្រប់គ្រាន់ដើម្បីដាក់ជូនព័ត៌មានបែបនេះឱ្យតុលាការពិចារណានោះ កសព មិនមានកាតព្វកិច្ចធ្វើបែបនេះបានទេ។ ក្នុងការធ្វើបែបនេះ ដោយសំអាងទៅលើវិធាន ២១(១)(ក) កសព អះអាងថា អវតក អនុវត្តប្រព័ន្ធគោលការណ៍ចំពោះមុខ[22]។ នេះជាការបកស្រាយច្រឡំយ៉ាងខ្លាំង។ វិធាន ២១(១)(ក) គ្រាន់តែរៀបរាប់ពីរបៀបដែលផ្នែកផ្សេងៗរបស់ អវតក គួរប្រតិបត្តិការដោយឯករាជ្យពីផ្នែកផ្សេងទៀត នៅក្នុងលក្ខណៈមួយដែល ត្រូវតែមាន"យុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ"[23]។ អវតក ជាតុលាការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលឡ[24] ហើយការប្រើប្រាស់ពាក្យថា "គោលការណ៍ចំពោះមុខ" នៅក្នុងវិធានផ្ទៃ

---

[20] កថាខណ្ឌទី ៧ នៃចម្លើយតបរបស់ កសព ។

[21] កថាខណ្ឌទី ៥ នៃចម្លើយតបរបស់ កសព ។

[22] ផ្ទុយទៅវិញ ICTY អនុវត្តប្រព័ន្ធសួរដេញដោលគ្នា។ សូមមើល *រដ្ឋអាជ្ញា តទល់នឹង Blaskic*, IT-95-12, សេចក្តីទៅលើសារណាស្នើសុំឱ្យមាន "ការដាក់ទណ្ឌកម្មលើរដ្ឋអាជ្ញា ដែលរំលោភវិធានទី ៦៨ នៃវិធានស្តីពីភស្តុតាង និងនីតិវិធី ច្រើនលើកច្រើនសារ ចុះថ្ងៃទី២៩ មេសា ១៩៩៨ កថាខណ្ឌទី ១៦។

[23] វិធានផ្ទៃក្នុង ២១(១)(ក) ។

[24] សូមមើល សំណុំរឿងរបស់ អៀង សារី លេខ ០០២/១២-០៩-២០០៧-អវតក/កសចស, ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ២០០៩ កថាខណ្ឌទី ១៣ ដែលក្នុងដីកាសម្រេចនេះ កសចស លើក

00356988



ក្នុង មិនបានធ្វើឱ្យវារួមចយនូវន័យខ្លឹមសារនៃប្រព័ន្ធច្បាប់ស៊ីវិលបានទេ ដូច្នេះហើយមិនអាចប្រែក្លាយទៅប្រព័ន្ធខំម៉ុនឡបានឡើយ។

9. វាលើសពីការជជែកតវ៉ា ដោយមិនគិតថាតើ អវតក អនុវត្តប្រព័ន្ធច្បាប់ស៊ីវិល ឬ ប្រព័ន្ធច្បាប់ខំម៉ុនឡ ព្រះរាជអាជ្ញាមានកាតព្វកិច្ចដែលមិនអាចលើកលែងបាន ដែលត្រូវតែទៀងត្រង់នឹងតុលាការគ្រប់ពេលជានិច្ច។ កាតព្វកិច្ចនេះរួមមាន ភារកិច្ចដាក់ជូននូវមូលដ្ឋានសំអាងផ្លូវច្បាប់ពាក់ព័ន្ធទាំងអស់ទៅនឹងបញ្ហានៅក្នុងវិវាទ ជាពិសេស មូលដ្ឋានសំអាងផ្លូវច្បាប់ដែលផ្ទុយនឹងប្រភពច្បាប់ ដែលកំពុងត្រូវបានយកសំអាងដើម្បីលើកតម្កើងជំហររបស់អ្នកណាម្នាក់។ ក្រមសីលធម៌វិជ្ជាជីវៈ ដែលភ្ជាប់កាតព្វកិច្ចព្រះរាជអាជ្ញាទាំងអស់នៃ កសព រួមទាំងសាស្ត្រាចារ្យ Scharf ផងដែរ កំណត់យ៉ាងច្បាស់ថា ព្រះរាជអាជ្ញាទាំងអស់ត្រូវលាតត្រដាងឱ្យបានពេញលេញនូវមូលដ្ឋានផ្លូវច្បាប់ជូនតុលាការ។ កាតព្វកិច្ច ដែលកើតមានឡើងឥតឈប់ឈរ ដើម្បីជួយដល់តុលាការក្នុងការស្វែងរកការពិតនេះ គឺមិនអាចជំទាស់តវ៉ានៅក្នុងចម្លើយតបរបស់ កសព បានឡើយ។ នៅក្នុងចម្លើយតបរបស់ខ្លួន កសព ចូលរួមពាក់ព័ន្ធយ៉ាងមានប្រសិទ្ធភាពនៅក្នុងកិច្ចកលបង្វែងដានដើម្បីបង្វែរស្មារតីយកចិត្តទុកដាក់ឱ្យងាកចេញឆ្ងាយពីអង្គហេតុ ដែលមិនអាចប្រកែកបានដែលថា ក) កសព បានដឹងពីមូលដ្ឋានសំអាងផ្លូវច្បាប់ ដែលបង្អន់ការអះអាងរបស់ខ្លួនដែលថា JCE គឺជាផ្នែកមួយនៃទម្លាប់ច្បាប់អន្តរជាតិ និង ខ) កសព បានឃុបឃិតគ្នាលាក់បំបាំងមូលដ្ឋានសំអាងផ្លូវច្បាប់នេះពី កសចស។ ជាការគួរឱ្យសោកស្តាយ នៅក្នុងដំណើរប្រកបដោយការគិតគូរយ៉ាងហ្មត់ចត់ កសព បានជ្រើសរើសយកសិល្បៈនៃល្បែងឈ្នះៗ (gamesmanship) ជាជាងសុចរិតភាព ដែលកំពុងបោកបញ្ឆោតឱ្យ កសចស យល់ខុស។ ទង្វើបែបនេះ គឺពុំមានក្រមសីលធម៌ ជាការមើលងាយ និង ត្រូវតែទទួលការដាក់ទណ្ឌកម្ម។

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានលើកឡើងនៅក្នុងចម្លើយតបនេះ មេធាវីការពារសូមស្នើ កសចស ដោយគោរពមេត្តាផ្តល់ដំណោះស្រាយដែលបានលើកឡើងនៅក្នុងសំណើសុំ។

---

ឡើងថា: "ក្រុមមេធាវីការពារក្តីមិនអាចលើកឡើងអំពីកង្វះការយល់ដឹងនៃប្រព័ន្ធច្បាប់ស៊ីវិល ដែលអាចអនុវត្តបាននៅចំពោះមុខ អវតក..."។

00356989



សូមលោកសហចៅក្រមទទួលយកចម្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០៨

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី